ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩

# របាយការណ៍ជាតិ
# ស្តីពី
# លទ្ធផលចុងក្រោយ

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

រាជធានីភ្នំពេញ កម្ពុជា

គាំទ្រដោយ : រាជរដ្ឋាភិបាលជប៉ុន

និង

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន (JICA)

ខែ ធ្នូ ឆ្នាំ ២០០៩

# មាតិកា

ទំព័រ

បុព្វកថា...iii

ផែនទី ១ ផែនទីប្រទេសកម្ពុជា... iv

តួលេខសង្ខេប...v

សេចក្តីព្រាង នៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩...I.១

ការវិភាគសង្ខេបនៃលទ្ធផលចុងក្រោយ...I.៣

**ផ្នែកទី ១ : តារាងទិន្នន័យកំរិតជាតិ**... II.១

តារាង ១-១: ចំនួនសហគ្រាសបែងចែកតាមទំហំនៃចំនួនបុគ្គលិកចូលរួមការងារ និងភេទអ្នកតំណាងសហគ្រាស កម្ពុជា (២០០៩)...II.២

តារាង ១-២: ចំនួនបុគ្គលិកចូលរួម បែងចែកតាមទំហំនៃចំនួនបុគ្គលិកចូលរួមការងារ និងភេទ កម្ពុជា (២០០៩)...II.៣

តារាង ១-៣: ចំនួនបុគ្គលិកចូលរួមបែងចែកតាមទំហំនៃចំនួនបុគ្គលិកចូលរួមការងារ និងភេទអ្នកតំណាងសហគ្រាស- កម្ពុជា (២០០៩)...II.៤

តារាង ១-៤: ចំនួនសហគ្រាសបែងចែកតាមទំហំនៃចំនួនបុគ្គលិកចូលរួមការងារ និងបានចុះបញ្ជីពាណិជ្ជកម្ម ឬមិនបានចុះបញ្ជីពាណិជ្ជកម្ម- កម្ពុជា (២០០៩)...II.៥

តារាង ១-៥: ចំនួនបុគ្គលិកចូលរួមបែងចែកតាមទំហំនៃចំនួនបុគ្គលិកចូលរួមការងារ និងបានចុះបញ្ជីពាណិជ្ជកម្ម ឬមិនបានចុះបញ្ជីពាណិជ្ជកម្ម- កម្ពុជា (២០០៩)...II.៦

តារាង ១-៦: ចំនួនសហគ្រាសបែងចែកតាមទំហំចំនួនបុគ្គលិកចូលរួមការងារ និងភាពជាម្ចាស់សហគ្រាស- កម្ពុជា (២០០៩)...II.៧

តារាង ១-៧: ភាគរយនៃចំនួនសហគ្រាសបែងចែកតាមទំហំនៃចំនួនបុគ្គលិកចូលរួមការងារ និងភាពជាម្ចាស់សហគ្រាស- កម្ពុជា (២០០៩)...II.៨

តារាង ១-៨: ចំនួនបុគ្គលិកចូលរួមបែងចែកតាមទំហំនៃចំនួនបុគ្គលិកចូលរួមការងារ និងភាពជាម្ចាស់សហគ្រាស កម្ពុជា (២០០៩)...II.៩

តារាង ១-៩: ភាគរយនៃចំនួនបុគ្គលិកចូលរួមបែងចែកតាមទំហំនៃចំនួនបុគ្គលិកចូលរួមការងារ និងភាពជាម្ចាស់សហគ្រាស កម្ពុជា (២០០៩)...II.១០

តារាង ២-១: ចំនួនសហគ្រាសបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទអ្នកតំណាងសហគ្រាស កម្ពុជា (២០០៩)...II.១១

តារាង ២-២: ភាគរយនៃចំនួនសហគ្រាសបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទអ្នកតំណាងសហគ្រាស កម្ពុជា (២០០៩)....................II.១២
តារាង ២-៣: ចំនួនបុគ្គលិកចូលរួមបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទ កម្ពុជា (២០០៩)....................II.១៣
តារាង ២-៤: ភាគរយ នៃចំនួនបុគ្គលិកចូលរួមបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទ សហគ្រាស កម្ពុជា (២០០៩)....................II.១៤
តារាង ២-៥: ចំនួនបុគ្គលិកចូលរួមបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទអ្នកតំណាងសហគ្រាស កម្ពុជា (២០០៩)....................II.១៥
តារាង ២-៦: ភាគរយនៃចំនួនបុគ្គលិកចូលរួមបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទអ្នកតំណាងសហគ្រាស កម្ពុជា (២០០៩)....................II.១៦
តារាង ២-៧: ចំនួនសហគ្រាសបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងបានចុះបញ្ជីក្រសួងពាណិជ្ជកម្ម ឬមិនបានចុះបញ្ជីពាណិជ្ជកម្ម កម្ពុជា (២០០៩)....................II.១៧
តារាង ២-៨: ភាគរយនៃចំនួនសហគ្រាសបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងបានចុះបញ្ជីក្រសួងពាណិជ្ជកម្ម ឬមិនបានចុះបញ្ជីពាណិជ្ជកម្ម កម្ពុជា (២០០៩)....................II.១៨
តារាង ២-៩: ចំនួនបុគ្គលិកចូលរួមបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងបានចុះបញ្ជីក្រសួងពាណិជ្ជកម្ម ឬមិនបានចុះបញ្ជីពាណិជ្ជកម្ម កម្ពុជា (២០០៩)....................II.១៩
តារាង ២-១០: ភាគរយនៃចំនួនបុគ្គលិកចូលរួមបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងបានចុះបញ្ជីក្រសួងពាណិជ្ជកម្ម ឬមិនបានចុះបញ្ជីពាណិជ្ជកម្ម កម្ពុជា (២០០៩)....................II.២០
តារាង ២-១១: ចំនួនសហគ្រាសបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងភាពជាម្ចាស់សហគ្រាស កម្ពុជា (២០០៩)....................II.២១
តារាង ២-១២: ចំនួនបុគ្គលិកចូលរួមបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងភាពជាម្ចាស់សហគ្រាស កម្ពុជា (២០០៩)....................II.២២
តារាង ២-១៣: ចំនួនសហគ្រាសបែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទអ្នកតំណាងសហគ្រាស កម្ពុជា (២០០៩)....................II.២៣
តារាង ២-១៤: ចំនួនបុគ្គលិកចូលរួម បែងចែកតាមផ្នែកចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទ កម្ពុជា (២០០៩)....................II.៣១
**ផ្នែកទី ២ : តារាងទិន្នន័យខេត្ត**....................III.១
តារាង ៣-១: ចំនួនសហគ្រាសបែងចែកតាមភេទអ្នកតំណាងសហគ្រាស គ្រប់ខេត្ត (២០០៩)....................III.២
តារាង ៣-២: ចំនួនបុគ្គលិកចូលរួមការងារតាមភេទ គ្រប់ខេត្ត (២០០៩)....................III.៣

តារាង ៣-៣: ចំនួនបុគ្គលិកចូលរួមបែងចែកតាមភេទអ្នកតំណាងសហគ្រាស គ្រប់ខេត្ត (២០០៩)....III.៤
តារាង ៣-៤: ចំនួនសហគ្រាសបែងចែកតាមសហគ្រាសបានចុះបញ្ជីក្រសួងពាណិជ្ជកម្ម និងមិនបានចុះបញ្ជី
ពាណិជ្ជកម្ម គ្រប់ខេត្ត (២០០៩)......................................................................III.៥
តារាង ៣-៥: ចំនួនបុគ្គលិកចូលរួមបែងចែកតាមសហគ្រាសបានចុះបញ្ជីក្រសួងពាណិជ្ជកម្ម និងមិនបានចុះ
បញ្ជីពាណិជ្ជកម្ម គ្រប់ខេត្ត (២០០៩)................................................................III.៦
តារាង ៣-៦: ចំនួនសហគ្រាសបែងចែកតាមភាពជាម្ចាស់សហគ្រាស គ្រប់ខេត្ត (២០០៩)..............III.៧
តារាង ៣-៧: ភាគរយនៃចំនួនសហគ្រាសបែងចែកតាមភាពជាម្ចាស់សហគ្រាស
គ្រប់ខេត្ត (២០០៩).... ...........................................................................III.៨
តារាង ៣-៨: ចំនួនបុគ្គលិកចូលរួមបែងចែកតាមភាពជាម្ចាស់សហគ្រាស គ្រប់ខេត្ត (២០០៩).........III.៩
តារាង ៣-៩: ភាគរយនៃចំនួនបុគ្គលិកចូលរួមបែងចែកតាមភាពជាម្ចាស់សហគ្រាស គ្រប់ខេត្ត
(២០០៩).............................................................................................III.១០
តារាង ៤-១: ចំនួនសហគ្រាសបែងចែកតាមទំហំបុគ្គលិកចូលរួម និងភេទអ្នកតំណាងសហគ្រាស
ខេត្តបន្ទាយមានជ័យ (២០០៩)......................................................................III.១១
តារាង ៤-២: ចំនួនបុគ្គលិកចូលរួមបែងចែកតាមទំហំបុគ្គលិកចូលរួម និងភេទអ្នកតំណាងសហគ្រាស
០១ ខេត្តបន្ទាយមានជ័យ (២០០៩).................................................................III.៣៥
តារាង ៥-១: ចំនួនសហគ្រាសបែងចែកតាមចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទអ្នកតំណាងសហគ្រាស
០១ ខេត្តបន្ទាយមានជ័យ (២០០៩).................................................................III.៥៩
តារាង ៥-២: ភាគរយនៃចំនួនសហគ្រាសបែងចែកតាមចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទអ្នកតំណាង
សហគ្រាស ០១ ខេត្តបន្ទាយមានជ័យ (២០០៩)...............................................III.៨៣
តារាង ៥-៣: ចំនួនបុគ្គលិកចូលរួមបែងចែកតាមចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទ
០១ ខេត្តបន្ទាយមានជ័យ (២០០៩)...........................................................III.១០៧
តារាង ៥-៤: ភាគរយនៃចំនួនបុគ្គលិកចូលរួមបែងចែកតាមចំណាត់ថ្នាក់ឧស្សាហកម្ម និងភេទ
០១ ខេត្តបន្ទាយមានជ័យ (២០០៩)...........................................................III.១៣១
**ផ្នែកទី ៣ : ឧបសម្ព័ន្ធ**................................................................................................ IV.១
**ឧបសម្ព័ន្ធ ១: តារាងសង្ខេបភូមិ**........................................................................... IV.២
**ឧបសម្ព័ន្ធ ២: តារាងសំរាប់ត្រួតពិនិត្យ និងគ្រប់គ្រងឯកសារ**................................................... IV.៣
**ឧបសម្ព័ន្ធ ៣: តារាងសំរាប់ចុះបញ្ជីសហគ្រាស**...................................................................... IV.៤

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ចំពោះការចេញផ្សាយលទ្ធផលផ្លូវការ នៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩ ដែលបានរៀបចំធ្វើឡើងយ៉ាងយកចិត្តទុកដាក់ចាប់ពី ថ្ងៃទី ៩ ខែ កុម្ភៈ រហូតដល់ថ្ងៃ ៨ មីនា ឆ្នាំ ២០០៩ ដោយកំណត់ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ ជាកាលបរិច្ឆេទយោង។ ជាប្រវត្តិសាស្រ្ត នេះគឺជាការធ្វើបញ្ជីសហគ្រាសដំបូងដែលបានរៀបចំឡើងដោយរាប់គ្រប់សហគ្រាសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រោមមូលដ្ឋានគ្រឹះនៃច្បាប់ស្តីពីស្ថិតិ ការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩ មានគោលបំណងចងក្រងស្ថិតិមូលដ្ឋានគ្រឹះស្តីពីសហគ្រាស និងបង្កើតជាបញ្ជីសហគ្រាសមេ ។ បញ្ជីសហគ្រាសមេផ្តល់ព័ត៌មានស្តីពីស្ថានភាពបច្ចុប្បន្ន នៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាហើយ និងបំរើដល់អ្នកប្រើប្រាស់ផ្សេងៗដូចជាអ្នកធ្វើគោលនយោបាយ មន្ត្រីរាជរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន ក្រុមអ្នកស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍។ បញ្ជីសហគ្រាសមេក៏ត្រូវបានប្រើប្រាស់ជាបញ្ជីជំរឿនសហគ្រាស ឆ្នាំ ២០១១ (Census Frame) និងសំរាប់ធ្វើជាបញ្ជីគំរូ (Sampling Frame) សំរាប់ការអង្កេតលំអិតលើគ្រឹះស្ថានអង្គភាពអាជីវកម្ម និងសហគ្រាស។

លទ្ធផលចុងក្រោយ បានចូលរួមចំណែកដល់ដំណើការអនុវត្តន៏ គោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការ និងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគាំទ្រការធ្វើផែនការដោយផ្អែកលើស្ថិតិជាមូលដ្ឋាន។ ខ្ញុំជឿជាក់ថាផ្នែកសាធារណៈសារៈពិតជាទទួលបានផលប្រយោជន៏យ៉ាងច្រើនអំពីលទ្ធផល នៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩ ដែលមានទំហំវិសាលភាពពេញលេញ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដែលបានជួយគាំទ្រជាបន្តបន្ទាប់ដល់សកម្មភាពស្ថិតិ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំក្រសួងផែនការ ក៏ដូចជាវិទ្យាស្ថានជាតិស្ថិតិ។

សូមថ្លែងអំណរគុណផងដែរចំពោះក្រសួងពាក់ព័ន្ធនានា ដូចជាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម និងបណ្តាស្ថាប័នរដ្ឋាភិបាលពាក់ពន្ធ័ផ្សេងទៀត ដែលបានជួយសំរួល និងដឹកនាំការងារធ្វើអោយការធ្វើបញ្ជីសហគ្រាស ឆ្នាំ ២០០៩ នេះ បានទទួលជោគជ័យ ។

សូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលជប៉ុន ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន **(JICA)** ដែលបានផ្តល់ជំនួយទាំងថវិកា និងបច្ចេកទេស ។ សូមថ្លែងអំណរគុណដល់លោក **ហ្វូមីហ៊ីកូ**

**នីស៊ី** ប្រធានទីប្រឹក្សា JICA លោកបណ្ឌិត **អាតស៊ុស៊ី អូតូម៉ូ** លោក **អាគីហ៊ីកូ អ៊ីតូ** លោក **យ៉ាស៊ូ អ៊ីស៊ីដា** និងជំនាញការ JICA ផ្សេងៗទៀតដែលបានចូលរួមក្នុងគំរោងនេះ ដែលបានប្រឹងប្រែងអស់ពីកំលាំងកាយចិត្តដើម្បីសម្រេចបានជោគជ័យក្នុងការអនុវត្តការងារ នៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសឆ្នាំ ២០០៩។

សូមថ្លែងអំណរគុណដល់ឯកឧត្តមអភិបាលរាជធានី ខេត្ត ព្រមទាំងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងប្រធានភូមិដែលបានជួយសំរួលកិច្ចការរដ្ឋបាលក្នុងការអនុវត្តការងារនៃការធ្វើបញ្ជីសហគ្រាសឆ្នាំ ២០០៩ ។ សូមថ្លែងអំណរគុណចំពោះម្ចាស់សហគ្រាស អាជីវករ ពាណិជ្ជករដែលបានផ្តល់ចំលើយ និងអ្នកយកព័តិមានវិទ្យុ ទូរទស្សន៍ ដែលបានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការ ជួយផ្សព្វផ្សាយអំពីការងារធ្វើបញ្ជីសហគ្រាសឆ្នាំ ២០០៩ ។

ការធ្វើបញ្ជីសហគ្រាសឆ្នាំ ២០០៩ គឺជាប្រតិបត្តិការស្ថិតិដ៏ធំមួយដែលអាចសម្រេចបានដោយមានការឧបត្ថម្ភ និងសហការយ៉ាងជិតស្និទ្ធពីគ្រប់អង្គភាពទាំងអស់។ ជោគជ័យធំមួយទៀត គឺបានមកពីការចូលរួមរបស់ម្ចាស់សហគ្រាសទាំងអស់ ( តូច មធ្យម ធំ ) ដែលបានចំណាយពេលវេលាដ៏មមាញឹក និងមានតំលៃដើម្បីផ្តល់ព័តិមានអំពីសហគ្រាសជូនមន្ត្រីសំភាសន៍ ។ សូមថ្លែងអំណរគុណដល់មន្ត្រីសំភាសន៍ មន្ត្រីត្រួតពិនិត្យ មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងផែនការទាំងអស់ដែលបានលះបង់ខិតខំប្រឹងប្រែងស្មោះត្រង់ក្នុងការងារ ។

សូមថ្លែងអំណរគុណចំពោះឯកឧត្តម **សន ស៊ីថន** អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានដឹកនាំប្រតិបត្តិការនៃការធ្វើបញ្ជីសហគ្រាសឆ្នាំ ២០០៩ ដោយមានជំនួយការពីអគ្គនាយករងលោក **ហោ ដារិទ្ធ** និងលោក **មិច កន្ទុល** ប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច លោក **សាំង ឡង់ឌី** ប្រធាននាយកដ្ឋានព័តិមានវិទ្យា លោក **ឃិន សុវលក្ខណ៍** អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច លោក **សូ តូនែរ** អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច និងលោក **គីម នេត** អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច និងមន្ត្រីវិទ្យាស្ថានជាតិស្ថិតិផ្សេងៗទៀត។

សូមថ្លែងអំណរគុណដល់មន្ត្រីទាំងអស់ ដែលបានចូលរួមធ្វើអោយការងារធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសឆ្នាំ ២០០៩ ទទួលបានជោគជ័យដ៏ធំធេង។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

ក្រសួងផែនការ

ភ្នំពេញ

ខែ ធ្នូ ឆ្នាំ ២០០៩

**ឆាយ ថន**

## Map 1. Cambodia by Province



# លទ្ធផលចុងក្រោយ នៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩

## តួលេខសង្ខេប

ចំនួនខេត្ត(១)........................................................................................................២៤

រួមបញ្ចូលរាជធានី ១

ចំនួនស្រុក ........................................................................................................១៩៣

រួមបញ្ចូលខណ្ឌចំនួន ៨ និងក្រុងចំនួន ២៦

ចំនួនឃុំ ........................................................................................................១,៦២១

រួមបញ្ចូលសង្កាត់ចំនួន ២០៤

ចំនួនភូមិ........................................................................................................១៤,០៧៣

ចំនួនសហគ្រាស........................................................................................................៣៧៦,៧៦១

 ៥នាក់ និងច្រើនជាង........................................................................................................៤៦,២៣៣

 ១០នាក់ និង ច្រើនជាង........................................................................................................១៣ ១២៣

 ១០០នាក់ និង ច្រើនជាង........................................................................................................៦៩២

 ១០០០នាក់ និង ច្រើនជាង........................................................................................................១០៦

 ភាគរយតំណាងស្ត្រី........................................................................................................៥០,១

 ទីប្រជុំជន (ភាគរយ) (២)........................................................................................................៣១,២

 ទីជនបទ (ភាគរយ)........................................................................................................៦៨,៨

ចំនួនបុគ្គលិកដែលបានចូលរួមក្នុងការងារ........................................................................................................១ ៤៦៩ ៧១២

 បុរស........................................................................................................៦២៦ ៧៨៣

 ស្ត្រី........................................................................................................៨៤២ ៩២៩

ចំនួនបុគ្គលិកដែលបានចូលរួមក្នុង ១ សហគ្រាស........................................................................................................៣.៩

ចំនួនសហគ្រាសក្នុង ១គីឡូម៉ែត្រការ៉េ........................................................................................................២,១

ចំនួនសហគ្រាសក្នុងបុគ្គលិក ១០០០នាក់........................................................................................................២៨,១

ប្រជាជនក្នុង ១សហគ្រាស........................................................................................................៣៩,៦

ចំនួនសហគ្រាសក្នុង ១០០០គ្រួសារ........................................................................................................១៣២,៦

ចំនួនគ្រួសារក្នុង ១គ្រួសារ........................................................................................................៧,៥

ចំនួនសហគ្រាស(៣) មានបុគ្គលិក ១០នាក់បានចូលរួម និងច្រើនជាង........................................................................................................១១ ៧៥៤

១- លទ្ធផលចុងក្រោយនេះ គឺផ្អែកលើដែនដីរដ្ឋបាលថ្មី ដែលបានសម្រេចចូលជាធរមាន ថ្ងៃទី ១២ ខែមករា ឆ្នាំ២០០៩

២- យោងតាមទំព័រទី ៧ នៃរបាយការណ៍លទ្ធផលចុងក្រោយ នៃជំរឿនប្រជារាស្រ្តទូទាំងប្រទេសកម្ពុជា ឆ្នាំ២០០៨

៣- សហគ្រាសនៅទីនេះមានន័យថា  គឺជាអង្គភាពអាជីវកម្មទោល ឬ ទីស្នាក់ការកណ្តាល និងសហគ្រាសដែលមានសាខា

# សេចក្តីព្រាង នៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា
# ឆ្នាំ ២០០៩

ការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជាឆ្នាំ ២០០៩ ចាប់ពីពេលនេះទៅមានពាក្យកាត់ថា “EL2009” ហើយពាក្យថា “NIS” មានន័យថា វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ។

**1- គោលបំណង**

១- ផលិតទិន្នន័យស្ថិតិនៃបំណែងចែកសហគ្រាស និងចំនួនបុគ្គលិកចូលរួមការងារតាមលក្ខណៈផ្សេងៗរបស់សហគ្រាស ដូចជាតាមវិស័យ ទំហំ លក្ខណៈច្បាប់ និងតំបន់ ។

២- បង្កើតនូវបញ្ជីមេសហគ្រាសដ៏ទូលំទូលាយថ្នាក់ជាតិមួយ ( National Comprehensive Frame) សំរាប់ការអង្កេតសហគ្រាស និងការជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១ ។

៣- បង្កើតនូវបញ្ជីជំរឿន ( Census Frame) សំរាប់ការជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១ ។

**2- កាលបរិច្ឆេទយោង**

ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៩

**3- រយៈពេលធ្វើសំភាសន៍**

ចាប់ផ្តើមពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៩

**4- បទប្បញ្ញត្តិ**

មាត្រាទី ៨ ឬ ទី ៩ នៃច្បាប់ស្តីពីស្ថិតិរបស់ប្រទេសកម្ពុជា

**5-តំបន់គ្របដណ្តប់**

ទូទាំងព្រះរាជាណាចក្រកម្ពុជា

**6-ភាពគ្របដណ្តប់**

គ្រប់សហគ្រាសទាំងអស់លើកលែងតែសហគ្រាសទោលក្នុងវិស័យ កសិកម្ម ព្រៃឈើ និងនេសាទ ដែលមាននៅក្នុងចំណាត់ថ្នាក់ឧស្សាហកម្មតាមស្តង់ដាអន្តរជាតិ **Revision 4** និងសហគ្រាសចល័ត ។

**និយមន័យសហគ្រាស :**

សហគ្រាស គឺអង្គភាពអាជីវកម្ម ឬជាផ្នែកមួយនៃអង្គភាពអាជីវកម្ម ដែលមានទីតាំងមួយជាក់លាក់ ហើយមានសកម្មភាពផលិតកម្មតែមួយ ឬមានសកម្មភាពផលិតកម្មសំខាន់ដែលបង្កើត តម្លៃបន្ថែមមួយផ្នែកធំ ( ផ្នែកស្ថិតិ នៃអង្គការសហប្រជាជាតិ) ។

## 7- រចនាសម្ព័ន្ធការងារ

ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) ⇨ មន្ត្រីសំរបសំរួលខេត្ត (ប្រធានមន្ទីរផែនការខេត្ត ក្រុងទាំង ២៤) ⇨ មន្ត្រីត្រួតពិនិត្យ (មន្ត្រីវិទ្យាស្ថានជាតិស្ថិតិចំនួន ៤០ នាក់ ) ⇨ មន្ត្រីសំភាសន៍ (មន្ត្រីផែនការខេត្ត ក្រុង ស្រុកខណ្ឌ ចំនួន ៣៥៨ នាក់)

## 8- វិធីសាស្ត្រ

មន្ត្រីសំភាសន៍ម្នាក់ធ្វើដំណើរទៅកាន់សហគ្រាស ហើយសំភាសន៍ម្ចាស់សហគ្រាស ឬបុគ្គលិកណាម្នាក់ដែលតំណាងអោយសហគ្រាស ដោយប្រើប្រាស់តារាងសំណួរធ្វើបញ្ជីសហគ្រាសឆ្នាំ ២០០៩ ។

## 9- តំបន់រដ្ឋបាល

លទ្ធផលចុងក្រោយនៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជាឆ្នាំ ២០០៩ ផ្អែកលើតំបន់រដ្ឋបាល ថ្មីដែលប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ។

## 10- ប្រធានបទសិក្សា

១- ឈ្មោះសហគ្រាស

២- ភេទអ្នកតំណាងរបស់សហគ្រាស

៣- អាស័យដ្ឋានសហគ្រាស

៤- បានចុះបញ្ជី ឬ មិនបានចុះបញ្ជី នៅក្រសួងពាណិជកម្ម

៥- ភាពជាម្ចាស់កម្មសិទ្ធ នៃអង្គភាពអាជីវកម្ម (លក្ខណៈផ្លូវច្បាប់)

៦- ទីស្នាក់ការកណ្តាល ឬ សាខា

៧- ចំនួនកម្មករចូលរួមការងារតាមភេទ

៨- ប្រភេទសកម្មភាពអាជីវកម្ម (ចំណាត់ថ្នាក់វិស័យឧស្សាហកម្ម)

៩- លេខទូរស័ព្ទរបស់សហគ្រាស

## 11- ការកែច្នៃទិន្នន័យ ការវិភាគ និងការផ្សព្វផ្សាយ

១-លទ្ធផលបណ្តោះអាសន្ននៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩ បានផ្សព្វផ្សាយ នៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ។

២-លទ្ធផលចុងក្រោយនៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជាឆ្នាំ ២០០៩ បានផ្សព្វផ្សាយ នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០០៩ ។

៣-របាយការណ៍វិភាគមួយចំនួនផ្សេងទៀតគ្រោង នឹងផ្សព្វផ្សាយបន្ទាប់ពីខែ មេសា ឆ្នាំ ២០១០ ។

**12 - ជំនួយបច្ចេកទេស**

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុនបានផ្តល់ជំនួយបច្ចេកទេសដល់គំរោងកែលំអស្ថិតិផ្លូវការនៅកម្ពុជា ចាប់ពី ខែ សីហា ឆ្នាំ ២០០៥ រហូលដល់ ខែ កញ្ញា ឆ្នាំ ២០១០ ។

**13 - ថវិកាចូលរួម**

១- ក្រសួងផែនការ

២- ថវិកាបរិភាគពីរដ្ឋាភិបាលជប៉ុន

៣- គំរោង **JICA** នៅវិទ្យាស្ថានជាតិស្ថិតិ

៤- គំរោង **JICA** នៅក្រសួងកិច្ចការនារី

**14 - ដំណាក់កាលត្រៀមបំរុង**

១- ការធ្វើបញ្ជីសហគ្រាសតាមផ្ទែក ឆ្នាំ ២០០៦ នៅរាជធានីភ្នំពេញ

២- ការធ្វើអង្កេតគំរូសហគ្រាសឆ្នាំ ២០០៧ នៅរាជធានីភ្នំពេញ

# ការវិភាគសង្ខេបលទ្ធផលចុងក្រោយ នៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេស កម្ពុជា ឆ្នាំ ២០០៩

ការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩ ត្រូវបានរៀបចំឡើងនៅថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០០៩ តាមកាលបរិច្ឆេទយោង។ ការធ្វើបញ្ជីសហគ្រាសឆ្នាំ ២០០៩ បានគ្របដណ្តប់គ្រប់សហគ្រាសទាំងអស់ដែលស្ថិតក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយជាលើកដំបូងនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ លទ្ធផលចុងក្រោយនៃ ការធ្វើបញ្ជីសហគ្រាសឆ្នាំ ២០០៩ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០០៩ បន្ទាប់ពីដំណើរការទិន្នន័យអស់រយៈពេល ១០ខែ ហើយត្រូវបង្ហាញដូចខាងក្រោមៈ

## ១. ចំនួនសហគ្រាសសរុបក្នុងប្រទេសកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាមានសហគ្រាសសរុបចំនួន ៣៧៦ ៧៦១ គិតត្រឹមថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០០៩ យោងតាមលទ្ធផលចុងក្រោយដែលទទួលបានពីការធ្វើបញ្ជីសហគ្រាសឆ្នាំ ២០០៩ ។ ចំនួនកម្មករចូលរួមការងារក្នុងសហគ្រាសទាំងអស់មាន ១ ៤៦៩ ៧១២ នាក់ ក្នុងនោះបុរសមាន ៦២៦ ៧៨៣ នាក់ ស្មើនឹង ៤២.៦% និងស្ត្រីមាន ៨៤២ ៩២៩ នាក់ ស្មើនឹង ៥៧.៤% ។ ចំនួនស្ត្រីចូលរួមក្នុងការងារច្រើនជាងបុរស។

**<u>និយមន័យសហគ្រាស</u>**

សហគ្រាស គឺជាអង្គភាពអាជីវកម្មមួយ ឬផ្នែកនៃអង្គភាពអាជីវកម្ម ដែលស្ថិតនៅលើទីតាំងមួយ ហើយនៅក្នុងនោះមានសកម្មភាពផលិតតែមួយ ឬច្រើនការឱ្យនិយមន័យនេះ គឺទៅតាមការឱ្យចំណាត់ថ្នាក់ឧស្សាហកម្ម តាមបទដ្ឋានអន្តរជាតិ (ISIC Rev 4) របស់អង្គការសហប្រជាជាតិ។

និយាយជាទូទៅ សហគ្រាសមានបីប្រភេទ : សហគ្រាសដែលមានទីតាំងជាក់លាក់ សហគ្រាសដែលអាចផ្លាស់ប្តូរទីកន្លែងបាន និង សហគ្រាសចល័ត។

- សហគ្រាសដែលមានទីតាំងជាក់លាក់ៈ មានន័យថាជាសហគ្រាសដែលដំណើរការសកម្មភាពអាជីវកម្មស្ថិតនៅទីកន្លែងច្បាស់លាស់ ហើយមានគ្រឿងបរិក្ខារជាប់លាប់។

- សហគ្រាសដែលអាចផ្លាស់ប្តូរកន្លែងបានៈ មានន័យថាជាសហគ្រាសដែលដំណើរការសកម្មភាពអាជីវកម្មជាប្រចាំ ហើយស្ថិតនៅទីកន្លែងមួយច្បាស់លាស់ ប៉ុន្តែអាចផ្លាស់ប្តូរទៅកន្លែងផ្សេងៗបានយ៉ាងស្រួល។

- សហគ្រាសចល័តៈ មានន័យថាជាសហគ្រាសដែលដំណើរការសកម្មភាពអាជីវកម្ម មិនមានទីកន្លែងស្ថិតនៅច្បាស់លាស់ ( អាជីវកម្មចល័ត)។

ដូច្នេះលទ្ធផលចុងក្រោយ នៃការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩ បានគ្របដណ្តប់លើតែសហគ្រាសដែលមានទីតាំងជាក់លាក់ និងសហគ្រាសដែលមានទីតាំងជាក់លាក់ប៉ុន្តែអាចផ្លាស់ប្តូរទីកន្លែងបានប៉ុណ្ណោះដោយមិនរាប់បញ្ចូលនូវសហគ្រាសចល័ត ។

## ភាពគ្របដណ្តប់

ការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩ បានគ្របដណ្តប់លើសហគ្រាសស្ទើរទាំងអស់ លើកលែង តែផ្នែក "កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" ( ផ្នែក A ) "សកម្មភាពគ្រួសារ" ( ផ្នែក T ) នៃ ISIC ។ ផ្នែកការទូត និងផ្នែកការិយាល័យរាជរដ្ឋាភិបាល រួមបញ្ចូលទាំងយោធាផង ដែលមិនត្រូវបានរាប់បញ្ចូលទេ ( ផ្នែក O ) នៃ ISIC ។

ប៉ុន្តែសហគ្រាសដែលដំណើរការនូវផលិតផលកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺត្រូវបានរាប់បញ្ចូល នៅក្នុងលទ្ធផលចុងក្រោយនេះ ជាផ្នែកផលិត ( ផ្នែក C នៃ ISIC) ។

## ការប៉ាន់ស្មាននៃចំនួនកម្មករចូលរួមក្នុងសហគ្រាសចល័ត

យោងតាមលទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជារាស្ត្រប្រទេសកម្ពុជាឆ្នាំ ២០០៩ បង្ហាញថាចំនួនមនុស្សដែលធ្វើការក្នុងសហគ្រាសគឺមាន ១.៩២ លាននាក់ ដោយមិនរាប់បញ្ចូល ផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ( ផ្នែក A) និងសកម្មភាពគ្រួសារ( ផ្នែក T) ។ តួលេខនេះរាប់បញ្ចូលទាំងមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែរ មានចំនួន ៣២០ 000 នាក់ ។

ដូច្នេះយើងអាចប៉ាន់ស្មានបានថា ចំនួនមនុស្សចូលរួមការងារក្នុងសហគ្រាស តាមការធ្វើបញ្ជីសហគ្រាសឆ្នាំ២០០៩ មានប្រមាណ ១.៤៧ លាននាក់ និង ១៣០ 000 នាក់ទៀត ធ្វើការក្នុងសហគ្រាសចល័ត ។ នោះយើងអាចនិយាយ បានថាការធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជា ឆ្នាំ ២០០៩ បានគ្របដណ្តប់ជាង ៩០% នៃមនុស្សដែលបានចូលរួម ការងារទាំងអស់យោងតាមផ្នែក ISIC ដែលបានលើកឡើងខាងលើ ។

ម្យ៉ាងវិញទៀតមានមនុស្សចូលរួមការងារក្នុងសហគ្រាសពីរ ឬច្រើន ។ ដូច្នេះចំនួនមនុស្សចូលរួមការងារក្នុងសហគ្រាសចល័តអាចច្រើនជាង ១៣០ 000នាក់ ។ ពីព្រោះលទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាសាស្ត្រប្រទេសកម្ពុជាឆ្នាំ ២០០៨ បង្ហាញថាចំនួនមនុស្សដែលមានការងារបន្ទាប់បន្សំ ឬការងារទី ២ មានប្រមាណ ៣៧០ 000 នាក់ ដូច្នេះចំនួនមនុស្សធ្វើការក្នុងសហគ្រាសចល័តអាចដល់ ៥០០ 000 នាក់ ។

-ប្រភព : សៀវភៅស្ថិតិកម្ពុជាឆ្នាំ ២០០៩

## ២. ប្រទេសកម្ពុជាមានចំនួនសហគ្រាសតិចជាង ធៀបនឹងទំហំប្រជារាស្ត្រ

ប្រទេសកម្ពុជាមានចំនួនសហគ្រាស ២៨.១ ក្នុងចំនួនមនុស្ស ១០០០ នាក់បើធៀបធៀប និង បណ្តាប្រទេសផ្សេងៗដូចជា ឥណ្ឌូលនេស៊ីមាន ៩៦.៧ ជប៉ុន ៤៦.៣ និងឡាវ ៣៥។ ក្នុងចំណោម ប្រទេសទាំងបួននេះ ប្រទេសកម្ពុជាមានចំនួនសហគ្រាសតិចជាងគេបើធៀបនឹងទំហំប្រជារាស្ត្ររបស់ខ្លួន។ វាហាក់បីដូចជាតំរូវឱមានគោលនយោបាយមួយដើម្បីលើកកំពស់ឱមានការបើកដំណើរការសហគ្រាសថ្មីៗ បន្ថែមទៀត។

-ចំនួនមនុស្សចូលរួមការងារក្នុងមួយសហគ្រាស គឺ ៣.៩ នាក់ បើប្រៀបនិងប្រទេសជប៉ុនមាន ៩.៩ នាក់ ,ឡាវមាន ១.២ នាក់ និង ឥណ្ឌូនេស៊ីមាន ២.៣ នាក់ ។

-ទំហំនៃមនុស្សចូលរួមការងារក្នុងមួយសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជានៅតែទាបជាង ប្រទេសជប៉ុន ប៉ុន្តែច្រើនជាងប្រទេសឡាវ និង ប្រទេសឥណ្ឌូនេស៊ី ។

ចំនួននេះអាចសន្និត់ការពិតថា ចំនួនមនុស្សចូលរួមការងារនៅក្នុងសហគ្រាសខ្នាតធំដែលមាន កម្មករចូលរួមចាប់ពី ១០០ នាក់ ឬលើសពីនេះមានចំនួនច្រើនជាង ២៥ ភាគរយនៃចំនួនសរុប ។

-មានការខុសគ្នាតិចតួចក្នុងការឱនិយមន័យសហគ្រាសក្នុងចំណោមប្រទេសទាំងបួននេះ។ ប្រភពទិន្នន័យ ESCAP Population Data Sheet 2008 និងជំរឿនសេដ្ឋកិច្ចឥណ្ឌូនេស៊ី ២០០៦ ជំរឿនប្រជាជនជប៉ុន ២០០៥ និងជំរឿនសហគ្រាសជប៉ុន ២០០៦ ហើយនឹងជំរឿនសេដ្ឋកិច្ចឡាវឆ្នាំ ២០០៦។

## ៣. ចំនួនសហគ្រាសដែលមានមនុស្សធ្វើការម្នាក់ ឬពីរនាក់

ចំនួនសហគ្រាសដែលមានមនុស្សម្នាក់ធ្វើការ គឺមាន ១១២០០០ សហគ្រាស ស្មើនឹង ២៩.៨% ហើយចំនួនសហគ្រាសដែលមានមនុស្សពីរនាក់ធ្វើការ គឺមាន ១៤៩០០០ សហគ្រាស ស្មើនឹង ៣៩.៦% ហេតុដូច្នេះ ចំនួនសហគ្រាសដែលមានមនុស្សចូលរួមការងារមានប្រហែល ៧០% នៃចំនួនសរុប។

ចំនួនសហគ្រាសដែលមានមនុស្សធ្វើការចាប់ពី ៥នាក់ឡើងទៅមាន ៤៦ ០០០ ស្មើនឹង ១២.៣% ហើយចំនួនមនុស្សធ្វើការចាប់ពី ១០នាក់ឡើងទៅមាន ១៣០០០ ស្មើនឹង ៣.៥% ចំនួនមនុស្សធ្វើការចាប់ពី ១០០នាក់ឡើងទៅមាន ៦៩២ ស្មើនឹង ០.២% ចំនួនមនុស្សធ្វើការចាប់ពី ១ ០០០នាក់ ឡើងទៅមានតែ ១០៦ ប៉ុណ្ណោះ នោះអាចនិយាយបានថាប្រទេសកម្ពុជាសហគ្រាសធំៗ គឺមានតិចតួចបំផុត។

ម៉្យាងវិញទៀតចំនួនមនុស្សធ្វើការក្នុងសហគ្រាសដែលមានចាប់ពី ៥នាក់ឡើងទៅគឺមាន ៨២៧០០ នាក់ ស្មើនឹង ៥៦.៣% គឺលើសពី ៥០% ហើយចំនួនមនុស្សធ្វើការចាប់ពី ១០នាក់ឡើងទៅមាន ៦២៦ ០០០ នាក់ ស្មើនឹង ៤២.៦% គឺលើស ៤០% ចំនួនមនុស្សធ្វើការចាប់ពី ១០០នាក់ ឡើងទៅមាន ៣៧៣ ០០០

នាក់ស្មើនឹង ២៥.៤% គឺលើស ២៥%បន្តិច ហើយចំនួនមនុស្សធ្វើការចាប់ពី ១000 នាក់ឡើងទៅមាន ២១៣ 000 នាក់ ស្មើនឹង ១៤.៥% ដូច្នេះទោះបីសហគ្រាសខ្នាតធំមានចំនួនតិចក៏ដោយតែចំនួនមនុស្សធ្វើការមានចំនួនច្រើនជាងគេ ។

## ៤. សហគ្រាសមានស្ត្រីជាតំណាង

សហគ្រាសជាច្រើនមានបុរសតំណាង ៥0% និងស្ត្រី ៥0%។ សហគ្រាសមានមនុស្សម្នាក់ធ្វើការមានចំនួន ៣៣ 000 សហគ្រាស ជាបុរស ហើយជាស្ត្រីមានចំនួន ៨0 000 សហគ្រាស ស្មើនឹង ៧0%។ ម៉្យាងវិញទៀតសហគ្រាសមានបុរសតំណាងមានជាង ៥0%នៃសហគ្រាសដែលមានមនុស្សធ្វើការពីរនាក់ឡើងទៅ ហើយសហគ្រាសខ្នាតធំមានសមាមាត្រភាគរយខ្ពស់ជាបុរសតំណាង។

## ៥. សហគ្រាសភាគច្រើនជាសហគ្រាសឯកជន (តារាង១.៦)

សហគ្រាសឯកជនមានចំនួន ៩៦.១% នៃសហគ្រាសសរុប មានន័យថាសហគ្រាសភាគច្រើនជាសហគ្រាសឯកជននៅក្នុងប្រទេសកម្ពុជា ម៉្យាងវិញទៀតចំនួនមនុស្សចូលរួមការងារក្នុងសហគ្រាសឯកជនមាន ១.២៧ លាននាក់ ស្មើនឹង ៨៦.៦% ។

សហគ្រាសភាគច្រើនគឺជាសហគ្រាសឯកជន មានប្រហែល ៩៦.១ភាគរយ នៃចំនួនសហគ្រាសសរុប។ ម្យ៉ាងទៀតចំនួបានមនុស្សចូលរួមការងារក្នុងសហគ្រាសឯកជនមានចំនួន ១,២៧លាននាក់ ដែលស្មើនឹង ៨៦.៦ ភាគរយ ។

## ៦.ពាណិជ្ជកម្មលក់ដុំ លក់រាយ និងជួសជុលរថយន្ត ម៉ូតូ

ក្រឡេកមើលចំនួនសហគ្រាសតាមផ្នែកនៃ ISIC គឺពាណិជ្ជកម្មលក់ដុំ លក់រាយ ជួសជុលរថយន្ត និងម៉ូតូ (ផ្នែក G) ជាផ្នែកដែលធំជាងគេបំផុតមានមនុស្សចូលរួមរហូតដល់ទៅ ១៩៨ 000នាក់ ស្មើនឹង ៥២.៦ ភាគរយ ។ បន្ទាប់មកសហគ្រាសផ្នែកផលិត (ផ្នែក C )មានចំនួនមនុស្សចូលរួមចំនួន ៨៥ 000 នាក់ស្មើនឹង ២២.៥ ភាគរយ រួមបញ្ចូលផ្នែកកិនស្រូវ (ចំណាត់ថ្នាក់កូដ ១0៦១)។ ការផលិតនូវសរសៃសូត្រអំបោះ និងតម្បាញ (ចំណាត់ថ្នាក់កូដ ១៣៩១) ការផលិតនូវសំលៀកបំពាក់ លើកលែងសំលៀកបំពាក់រោមសត្វ (ចំណាត់ថ្នាក់កូដ ១៤១0) ការផលិតស្រា ( ចំណាត់ថ្នាក់កូដ ១១0២) ការផលិតស្ករស (ចំណាត់ថ្នាក់កូដ ១0៧២) ។ល។

បន្ទាប់មកសកម្មភាពសេវាកម្មម្ហូបអាហារ ( ផ្នែក I ) មានចំនួនមនុស្សចូលរួមការងារ ២៩ ០០០ នាក់ស្មើនឹង ៧.៨ ភាគរយ ហើយសកម្មភាពសេវាកម្មផ្សេងៗទៀត ( ផ្នែក S) មានមនុស្សចូលរួមចំនួន ២៦ ០០០ នាក់ស្មើនឹង ៦.៧ ភាគរយ រាប់បញ្ចូលទាំងផ្នែកកែសម្ផស្ស និងកាត់សក់ ( ចំណាត់ថ្នាក់កូដ ៩៦០២) ។ ផ្នែកអប់រំមាន ( ផ្នែក P ) មានមនុស្សចូលរួមការងារចំនួន ៩ ០០០ នាក់ស្មើនឹង ២.៤ ភាគរយ រាប់បញ្ចូលទាំងការអប់រំថ្នាក់មតេយ្យសិក្សា និងបឋមសិក្សា (ចំណាត់ថ្នាក់កូដ ៨៥១០) និងកំរិតមធ្យមសិក្សា ( ចំណាត់ថ្នាក់ កូដ ៨៥២១) ។

ក្នុងនោះចំនួនអ្នកធ្វើការតាមផ្នែក ISIC ( ផ្នែកផលិត ផ្នែក C) គឺជាផ្នែកដែលធំជាងគេបំផុតមានអ្នកចូលរួមការងារ ៥២៨,០០០ នាក់ស្មើនឹង ៣៥.៩ ភាគរយ បន្ទាប់គឺផ្នែកពាណិជ្ជកម្មលក់ដុំ និងលក់រាយ ជួសជុលរថយន្ត និងម៉ូតូ ( ផ្នែក G ) មាន ៤៣២ ០០០ នាក់ស្មើនឹង ២៩.៤ ភាគរយ ហើយផ្នែកសេវាកម្មដ៏ទៃទៀត ( ផ្នែក S ) មាន ១២៤ ០០០ នាក់ស្មើនឹង ៨.៤ ភាគរយ ផ្នែកសិក្សាអប់រំ ( ផ្នែក P ) មាន ១២៣ ០០០ នាក់ ស្មើនឹង ៨.៤ភាគរយ និងផ្នែកសកម្មភាពសេវាកម្មម្ហូមអាហារ និងការស្នាក់នៅ ( ផ្នែក I ) មាន ១១៣ ០០០ នាក់ស្មើនឹង ៧.៧ ភាគរយ ។

## ៧. សហគ្រាសចំនួន ៣០ភាគរយនៃចំនួនសហគ្រាសសរុប គឺមានទីតាំងស្ថិតនៅតំបន់ទីប្រជុំជន

ចំនួនសហគ្រាសដែលមានទីតាំងស្ថិតនៅតំបន់ទីប្រជុំជនមាន ១១៧ ០០០ ស្មើនឹង ៣១.២ភាគរយនៃចំនួនសហគ្រាសសរុប ។ ចំណែកឯនៅតំបន់ជនបទមាន ២៥៩ ០០០ ស្មើនឹង ៦៨.៨ភាគរយ មានចំនួនលើស ២ភាគ៣ នៃចំនួនសហគ្រាសសរុប ។

ម្យ៉ាងវិញទៀតបើយើងក្រឡេកមើលសហគ្រាសខ្នាតធំដែលមានមនុស្សធ្វើការចាប់ពី ១០០ នាក់ឡើងទៅគឺមាន ៥១៦ សហគ្រាសនៅក្នុងតំបន់ទីប្រជុំជនស្មើនឹង ៧៤.៦ ភាគរយ ហើយនៅទីជនបទមានត្រឹមតែ ១៧៦ សហគ្រាសប៉ុណ្ណោះដែលស្មើនឹង ២៥.៤ ភាគរយ ។

ហេតុដូច្នេះឃើញថា ៣ភាគ៤ នៃសហគ្រាសខ្នាតធំ គឺស្ថិតនៅតំបន់ទីប្រជុំជន ។ ចំនួននេះផ្ទុយពីចំនួនសហគ្រាសបែងចែកខាងលើ ។

### និយមន័យទីប្រជុំជន

រាល់ឃុំ- សង្កាត់ ដែលមានចរិកលក្ខណៈបីដូចខាងក្រោមនេះ គឺអាចចាត់ទុកបានជាទីប្រជុំជន :

១-ដងស៊ីតេប្រជាជនលើសពី ២០០ នាក់ក្នុង ១ គីឡូម៉ែត្រការ៉េ

២-ភាគរយនៃអ្នកធ្វើការជាបុរសក្នុងវិស័យកសិកម្មតិចជាង ៥០ ភាគរយ ហើយនិង

៣-ចំនួនប្រជាជនសរុបនៅក្នុងឃុំ-សង្កាត់ លើសពី ២០០០ នាក់ ។

មើលទំព័រទី៧ នៃរបាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជារាស្ត្រប្រទេសកម្ពុជា ឆ្នាំ២០០៨ ។

## ៨. ចំនួនសហគ្រាសខ្នាតធំនៅក្នុងប្រទេសកម្ពុជាមានចំនួន ១២ ០០០

នៅប្រទេសកម្ពុជាមានសហគ្រាសខ្នាតធំចំនួន ១២ ០០០ ហើយមានចំនួនមនុស្សចូលរួមការងារប្រមាណ ៦៤ ០០០ នាក់ ស្មើនឹង ៤៣.៥ ភាគរយ នៃចំនួនសរុប ចំនួននេះលើស ៤០ ភាគរយ ។

## និយមន័យសហគ្រាសខ្នាតធំ

រាល់សហគ្រាស ឬក្រុមនៃសហគ្រាសដែលមានចរិកលក្ខណៈពីរយ៉ាងដូចខាងក្រោម ទើបអាចចាត់ទុកថាជាសហគ្រាស :

១-សហគ្រាសទោលដែលមានមនុស្សចូលរួមការងារចាប់ពី ១០ នាក់ឡើងទៅ ។

២-ក្រុមនៃសហគ្រាសដែលមានទីស្នាក់ការកណ្ដាល និងមានសាខា ១ឡើងទៅ

-ចំនួនមនុស្សចូលរួមការងារក្នុងមួយសហគ្រាសគឺ ៣.៩នាក់ បើប្រៀបធៀបនឹងប្រទេសជប៉ុនមាន ៩.៩ នាក់ ,ឡាវមាន ១.២ នាក់ និង ឥណ្ឌូនេស៊ីមាន ២.៣ នាក់ ។

-ទំហំនៃមនុស្សចូលរួមការងារក្នុងមួយសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជានៅតែទាបជាងប្រទេសជប៉ុន ប៉ុន្តែច្រើនជាងប្រទេសឡាវ និងប្រទេសឥណ្ឌូនេស៊ី ។

ចំនួននេះអាចសន្និដ្ឋានការពិតថា ចំនួនមនុស្សចូលរួមការងារនៅក្នុងសហគ្រាសខ្នាតធំមានចំនួនឬច្រើនជាង ដែលមានចំនួនច្រើនជាង ២៥ ភាគរយនៃចំនួនសរុប ។

**ក្រាហ្វិក ១: ចំនួនសហគ្រាសបែងចែកតាមភេទអ្នកតំណាងសហគ្រាស គ្រប់ខេត្ត (២០០៩)**



ក្រាហ្វិក ២: ចំនួនបុគ្គលិកចូលរួមការងារតាមភេទ គ្រប់ខេត្ត (២០០៩)



## ក្រាហ្វិក ៣ : ចំនួនបុគ្គលិកចូលរួមការងារក្នុងមួយសហគ្រាស បែងចែកតាមខេត្ត (២០០៩)



**ក្រាហ្វិក ៤: ចំនួនសហគ្រាសក្នុងមនុស្ស១.០០០នាក់ បែងចែកតាមខេត្ត (២០០៩)**



**ក្រាហ្វិក ៥: ចំនួនសហគ្រាសក្នុងមនុស្ស ១០ នាក់ ឬច្រើន ចូលរួមក្នុងការងារបែងចែក តាមខេត្ត (២០០៩)**



**ក្រាហ្វិក ៦: ភាគរយនៃស្ត្រីធៀបចំនួនសរុបអ្នកតំណាងសហគ្រាស បែងចែកតាមខេត្ត (២០០៩)**



**ក្រាហ្វិក ៧: ភាគរយនៃស្ត្រីធៀបចំនួនសរុបអ្នកចូលរួមក្នុងការងារ បែងចែកតាមខេត្ត (២០០៩)**



**ក្រាហ្វិក ៨: ចំនួនសហគ្រាសនៅក្នុងវិស័យកម្មន្តសាលនៃ ISIC បែងចែកតាមខេត្ត (២០០៩)**



**ក្រាហ្វិក ៩: ចំនួនសហគ្រាសនៅក្នុងវិស័យ " សេវាកម្មម្ហូបអាហារ និងស្នាក់អាស្រ័យ " នៃ ISIC បែងចែកតាមខេត្ត (២០០៩)**



**ក្រាហ្វិក ១០: ចំនួនសហគ្រាសនៅក្នុងវិស័យអប់រំ នៃ ISIC បែងចែកតាមខេត្ត (២០០៩)**

